ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូង

ខេត្តស្វាយរៀង

សំណុំរឿងរដ្ឋប្បវេណីលេខៈ ១៥៤

ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៩

សាលក្រមលេខ: ១១៦ (ខ)

ចុះថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០២០

# តាងនាមប្រជារាស្ត្រខ្មែរ

# សាលាដំបូងខេត្តស្វាយរៀង

បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ នៅថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០២០ និងប្រកាសជាសាធារណៈនៅថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០២០ ដោយមានសមាសភាពចូលរួមដូចខាងក្រោម៖

## ចៅក្រមជំនុំជំរះ

លោកស្រី [redacted] ជាចៅក្រមសាលាដំបូងខេត្តស្វាយរៀង

## ក្រឡាបញ្ជីសវនាការ

លោក [redacted] ជាក្រឡាបញ្ជីសាលាដំបូងខេត្តស្វាយរៀង

**ភាគីនៃបណ្តឹង:**

-**ដើមចោទ** ឈ្មោះ [redacted] **ញ៉ឹម** ភេទប្រុស អាយុ៦១ឆ្នាំ ជនជាតិខ្មែរ មុខរបរមន្ត្រីកងរាជអាវុធហត្ថ និងប្រពន្ធឈ្មោះ [redacted] **ម៉ាលីស(ហៅ សាម៉ា)** ភេទស្រី អាយុ៦៥ឆ្នាំ ជនជាតិខ្មែរ មានអាស័យដ្ឋាន[redacted] ។

-**សហចុងចម្លើយ** ឈ្មោះ [redacted] **សំបូរ** ( [redacted] **មុ**) ភេទស្រី អាយុ៦៣ឆ្នាំ ជនជាតិខ្មែរ និងឈ្មោះ [redacted] **សារ៉េត**( [redacted] **រ៉េត**) ភេទប្រុស អាយុ៣៨ឆ្នាំ មានអាស័យដ្ឋានបច្ចុប្បន្ន[redacted]ដោយមានលោក [redacted]ជាមេធាវីតំណាងដោយអាណត្តិ។

## អង្គហេតុ និងចំណុចវិវាទ

**១-ការទាមទាររបស់ដើមចោទ:**

តាមពាក្យបណ្តឹងរបស់ដើមចោទឈ្មោះ [redacted] **ញ៉ឹម និង** [redacted] **ម៉ាលីស** ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៩ ប្តឹងសុំឱ្យតុលាការចេញសាលក្រមសម្រេច ដូចខាងក្រោម:

១.ប្រគល់ដីស្រែទំហំ ២ហិកតា ដែលមានទីតាំងស្ថិតនៅភូមិថ្មី ឃុំខ្សែត្រ ស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង មកខ្លួនជាជាម្ចាស់កម្មសិទ្ធិតទៅ ។

២.ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់សហចុងចម្លើយ។

**២-ការអះអាងរបស់គូភាគី:**

**២.១ ការអះអាងរបស់ដើមចោទ:**

-សហចុងចម្លើយឈ្មោះ [redacted]សាវ៉េត បានថ្លែងការណ៍ថា ចំពោះដី០២ហិកតានេះ ខ្លួនមិនបានដឹងច្បាស់ថា ជាដីរបស់នរណាទេ គ្រាន់តែខ្លួនតាំងពីធំដឹងក្តីមកខ្លួនធ្វើស្រែលើដីនេះតាំងពីនោះមករហូតដល់ចុងឆ្នាំ២០១៩ ទើបមានការទាមទារ។

-មេធាវីតំណាងដោយអាណត្តិឱ្យសហចុងចម្លើយ បានធ្វើសេចក្តីសន្និដ្ឋានថា សូមគោរពលោកស្រីចៅក្រម និងអង្គសវនាការទាំងមូល ខ្លួន [redacted] ជាមេធាវីតំណាងអាណត្តិឱ្យចុងចម្លើយក្នុងសំណុំរឿងលេខ១៥៤ ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៩ ដោយសារក្នុងនីតិវិធីត្រៀមបានកំណត់ចំណុចវិវាទថា តើដីចំនួន០២ហិកតា ដែលដើមចោទទាមទារ ជាកម្មសិទ្ធិរបស់ដើមចោទឬរបស់ចុងចម្លើយ ។ ដូច្នេះក្នុងសំណុំរឿងនេះ ខ្លួនសូមធ្វើសេចក្តីសន្និដ្ឋានដូចតទៅ ៖ ពាក់ព័ន្ធនឹងចំណុចទី១ ដែលដើមចោទទាមទារដីចំនួន០២ហិកតា មានទីតាំងស្ថិតនៅភូមិថ្មី ឃុំខ្សែត្រ ស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង បើតាមនីតិវិធីត្រៀម និងក្នុងពេលទាញហេតុផលនេះ គឺបានបញ្ជាក់ថា ដើមចោទ បច្ចុប្បន្នក៏ដូចពីមុន ក៏មិនទាន់ដឹងច្បាស់ពីដីដែលខ្លួនទាមទារស្ថិតនៅភូមិថ្មី ឬភូមិសាម៉ដែរ ។ ចំពោះបញ្ហាដែលគាត់បានដឹងគឺស្ថិតនៅ ពេលដែលគាត់បានដាក់ពាក្យបណ្តឹង ទើបគាត់អាចបញ្ជាក់បានថា ដីនេះស្ថិតនៅភូមិសាម៉ ។ ទី២ បើផ្អែកតាមការសួរដេញដោល ក៏ដូចជាការបង្ហាញភស្តុតាង គឺខាងដើមចោទ គឺគាត់បានបញ្ជាក់ថា គាត់បានធ្វើស្រែលើដីចំនួន០២ហិកតានេះ ដែលមិនច្បាស់ពីទីតាំង ព្រំប្រទល់ ក្នុងរយៈពេលមួយឆ្នាំដំបូង ដោយគាត់បានបំពេញការងារក្នុងខេត្តស្វាយរៀង បន្ទាប់មកនៅក្នុងឆ្នាំ១៩៨៤ តទៅ គាត់បានបោះបង់ដីនេះចោល ។ ចំណុចទី៣ ចំពោះការសួរដេញដោលចំពោះសាក្សី ក៏បានបញ្ជាក់យ៉ាងច្បាស់ដែរថា ដីចំនួន០២ហិកតាដែលស្ថិតនៅភូមិសាម៉នេះ គឺជារបស់ចុងចម្លើយជាអ្នកកាន់កាប់តាំងពីឆ្នាំ១៩៨៤ រហូតដល់បច្ចុប្បន្ន។ ដោយឡែកតែចម្លើយសាក្សីរបស់លោក[redacted]ដែលជាមេភូមិសាម៉ ក៏គាត់បានបញ្ជាក់យ៉ាងច្បាស់ដែរថា ដីនេះគឺចុងចម្លើយជាអ្នកកាន់កាប់តាំងពីដើមរហូតដល់បច្ចុប្បន្ន។ ត្រង់ចំណុចនេះ ខ្លួនសូមបញ្ជាក់ពីភស្តុតាង គឺលិខិតបញ្ជាក់ពីការកាន់កាប់អចលនវត្ថុ ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០២០ នោះ គឺខាងឃុំគាត់បានទទួលស្គាល់ថា ដីនេះ ចុងចម្លើយជាអ្នកកាន់កាប់តាំងពីឆ្នាំ១៩៨៣មកម្លេះ ។ ដោយផ្អែកទៅលើអង្គច្បាប់វិញ យោងតាមច្បាប់ភូមិបាលឆ្នាំ២០០១ ត្រង់មាត្រា៣០ បានបញ្ជាក់យ៉ាងច្បាស់ថា ភាគីដែលគាត់កាន់កាប់អចលនទ្រព្យចាប់ពី៥ឆ្នាំឡើងទៅ ដោយមិនមានការប្តឹងទាស់ ឬមានការទាមទារពីតតិយជនទេ គឺ អាចក្លាយជាភោគៈស្របច្បាប់លើដីនេះបាន ។ ដូច្នេះបើសន្និដ្ឋានសរុបមកវិញ គឺខ្លួនសូមសំណូមពរឱ្យលោកស្រីចៅក្រមមេត្តាច្រានចោលការទាមទាររបស់ខាងដើមចោទ និងប្រគល់ដីខាងលើមកឱ្យចុងចម្លើយកាន់កាប់បន្ត។

**ភស្តុតាងរបស់សហចុងចម្លើយរួមមាន៖**

- សៀវភៅគ្រួសារ ខ៤/០៥៤៩៦ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២០ ។
- លិខិតបញ្ជាក់សិទ្ធិកាន់កាប់អចលនទ្រព្យលេខ០២៨/២០ ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០២០ ។

## ចំណុចវិវាទ

នៅក្នុងរឿងនេះចំណុចវិវាទគឺ: ការកំណត់អំពីកម្មសិទ្ធិលើដីទំហំ០២ហិកតា តើដីវិវាទនេះជាកម្មសិទ្ធិរបស់នរណា?

## សំអាងហេតុ

តាមលទ្ធផលនៃការសាកសួរសាមីភាគី សាកសួរសាក្សី និងការពិនិត្យភស្តុតាងនានា ក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ឃើញថា:

គាត់បានបញ្ជាក់យ៉ាងច្បាស់ដែរថា ដីនេះគឺចុងចម្លើយជាអ្នកកាន់កាប់តាំងពីដើមរហូតដល់បច្ចុប្បន្ន។ ត្រង់ចំណុចនេះ ខ្លួនសូមបញ្ជាក់ពីភស្តុតាង គឺលិខិតបញ្ជាក់ពីការកាន់កាប់អចលនវត្ថុ ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០២០ នោះ គឺខាងឃុំគាត់បានទទួលស្គាល់ថា ដីនេះ ចុងចម្លើយជាអ្នកកាន់កាប់តាំងពីឆ្នាំ១៩៨៣មកម្លេះ ។ ដោយផ្អែកទៅលើអង្គច្បាប់វិញ យោងតាមច្បាប់ភូមិបាលឆ្នាំ២០០១ ត្រង់មាត្រា៣០ បានបញ្ជាក់យ៉ាងច្បាស់ថា ភាគីដែលគាត់កាន់កាប់អចលនទ្រព្យចាប់ពី៥ឆ្នាំឡើងទៅដោយមិនមានការប្ដឹងទាស់ ឬមានការទាមទារពីតតិយជនទេ គឺ អាចក្លាយជាភោគៈស្របច្បាប់លើដីនេះបាន ។ ដូច្នេះបើសន្និដ្ឋានសរុបមកវិញ គឺខ្លួនសូមសំណូមពរឱ្យលោកស្រីចៅក្រមមេត្តាច្រានចោលការទាមទាររបស់ខាងដើមចោទ និងប្រគល់ដីខាងលើមកឱ្យចុងចម្លើយកាន់កាប់បន្ត។

សាក្សីឈ្មោះ [redacted] រី បានថ្លែងការណ៍បំភ្លឺថា ខ្លួនបានស្បថរួចហើយ ។ កាលនោះខ្លួនដឹង ដោយសារសុទ្ធតែពូមីងខ្លួន មេភូមិប្រាប់ខ្លួន ហើយដីនេះជាដីសហគមន៍សល់ ហើយឈ្មោះ [redacted] ញ៉ឹម បានសុំដី០២ហិកតា ហើយមេឃុំ មេភូមិឱ្យគាត់ ឈ្មោះ [redacted] ញ៉ឹម ជាទាហ៊ាន ។ ឈ្មោះ ម៉ៅ ញ៉ឹម ធ្វើលើដីនេះបាន០១ឆ្នាំ ក្រោយមកគាត់ក៏បានទៅភ្នំពេញ មិនដែលឃើញគាត់មកធ្វើទៀតទេ គឺបងគាត់ជាអ្នកធ្វើ ។

សាក្សីឈ្មោះ [redacted] សម្បត្តិ បានថ្លែងការណ៍បំភ្លឺថា ខ្លួនបានសម្បថរួចហើយ។ ខ្លួនជាបងប្អូនម្ដាយឈ្មោះ [redacted] ឫ ។ ដំបូងឡើយដីនេះរបស់ឈ្មោះ [redacted] ញ៉ឹម បានសុំយកមកធ្វើស្រែ ក្រោយមកគាត់ក៏បានចែកឱ្យប្អូន ធ្វើស្រែរហូតទាំងអស់គ្នា។

សាក្សីឈ្មោះ [redacted] សាយ បានថ្លែងការណ៍បំភ្លឺថា ខ្លួនបានស្បថរួចហើយ។ ខ្លួនជាមេភូមិសាម៉ ។ ដំបូងឡើយឈ្មោះ [redacted] ញ៉ឹម មកសុំដីគោលនយោបាយ ពេលនោះខាងភូមិឃុំ បានឱ្យដីចំនួន០២ហិកតាឱ្យគាត់កាន់កាប់ តែក្រោយមកគាត់ឱ្យនរណាខ្លួនមិនដឹងទេ ។ កន្លងមកខ្លួនដឹងថា គាត់ឧស្សាហ៍ទៅលេងរហូត។ ពេលនោះខ្លួនបានឱ្យដីគាត់ក្នុងឆ្នាំ១៩៨២ ហើយឆ្នាំ១៩៨៣ គាត់ធ្វើ ។ ពីមុនដីនេះ វាជាប់ព្រំប្រទល់ភូមិថ្មី ភូមិសាម៉ តែក្រោយគេកំណត់ព្រំប្រទល់ទៅជាដីនៅភូមិសាម៉។

សាក្សីឈ្មោះ [redacted] សង្ហា បានថ្លែងការណ៍បំភ្លឺថា ខ្លួនបានស្បថរួចហើយ។ ពេលនោះ លោក [redacted] ញ៉ឹម ជាទាហ៊ានហើយក៏យកចូលទាហ៊ានដែរ ពេលនោះមេភូមិមេឃុំ ប្រគល់ដី០២ហិកតាឱ្យទៅលោក [redacted] ញ៉ឹម ពេលនោះខ្លួនជាកូនទាហ៊ានគាត់ ទៅធ្វើស្រែឱ្យគាត់ដែរ ។ នៅក្នុងឆ្នាំ១៩៨២ ១៩៨៣ ក្រោយ លោក [redacted] ញ៉ឹម ក៏ឱ្យបងប្អូនធ្វើស្រែយកស្រូវរហូតទៅហើយគាត់ឧស្សាហ៍ចុះឡើងទៅមើលដីគាត់ដែរ ។

សាក្សីឈ្មោះ [redacted] សំណាង បានថ្លែងការណ៍បំភ្លឺថា ខ្លួនបានស្បថរួចហើយ។ ខ្លួនត្រូវជាពូបង្កើតរបស់ដើមចោទ។ ពេលនោះខ្លួនក៏ចូលជាទាហ៊ានជាមួយឈ្មោះ [redacted] ញ៉ឹម ។ នៅឆ្នាំ១៩៨២-១៩៨៣ គាត់មានដីស្រែនោះមែន ព្រោះខ្លួនទៅជួយធ្វើស្រែនោះដែរបានប្រហែល១ឆ្នាំ ហើយក្រោយមកខ្លួនក៏ឧស្សាហ៍ចុះឡើងជាមួយក្មួយទៅមើលដីនេះដែរ។

សាក្សីឈ្មោះ [redacted] ចាន់ណា បានថ្លែងការណ៍បំភ្លឺថា ខ្លួនបានស្បថរួចហើយ។ កាលនោះខ្លួននៅជាមួយគាត់តាំងពីឆ្នាំ១៩៨០ ជាងមក និងបានជួយធ្វើស្រែ ហាលស្រូវឱ្យគាត់ ហើយក្រោយមកក៏ដឹងថា ដីគាត់០២ហិកតា គាត់ធ្វើលើដីបានជាងមួយឆ្នាំ ហើយគាត់ទៅភ្នំពេញ ក្រោយមកទៀតក៏ឃើញបងគាត់ធ្វើស្រូវអង្គឱ្យគាត់រហូត។



Scanned with CamScanner

សោគផលគ្នាជាហូរហែររហូតមក ។ ផ្អែកតាមគោលការណ៍ឆន្ទៈរបស់ភាគី សហចុងចម្លើយក៏បានធ្លាប់និយាយថាផ្តល់ដី០១ហិកតា ហើយដើមចោទក៏បានបង្ហាញឆន្ទៈទទួលយកដី០១ហិកតាផងដែរ ។ គប្បីតុលាការពិនិត្យនិងសម្រេចតាមច្បាប់ ។

ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ដើមចោទជាអ្នករ៉ាប់រង តាមមាត្រា៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

## សេចក្តីសម្រេចបញ្ចប់

១-ប្រគល់ដីស្រែទំហំ០២ហិកតា ដែលមានព្រំប្រទល់ ខាងជើងទល់នឹងភ្លឺស្រែ ខាងត្បូងទល់នឹង [redacted] ទិត ខាងកើតទល់នឹងភ្លឺស្រែ និងខាងលិចទល់នឹងភ្លឺស្រែ មានទីតាំងស្ថិតនៅភូមិសាម៉រ ឃុំខ្សែត្រ ស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង ក្នុងនោះដីស្រែទំហំ០១ហិកតា មានព្រំប្រទល់ ខាងជើងទល់នឹងភ្លឺស្រែ ខាងត្បូងទល់នឹង [redacted] ទិត ខាងកើតទល់នឹងភ្លឺស្រែ និងខាងលិចទល់នឹងសហចុងចម្លើយឈ្មោះ [redacted] បូ និង [redacted] សារ៉េត ឱ្យទៅភាគីដើមចោទគ្រប់គ្រងជាម្ចាស់កម្មសិទ្ធិ និងដីស្រែទំហំ០១ហិកតាទៀត មានព្រំប្រទល់ ខាងជើងទល់នឹងភ្លឺស្រែ ខាងត្បូងទល់នឹង [redacted] ទិត ខាងកើតទល់នឹងដើមចោទឈ្មោះ [redacted] ញ៉ឹម និង [redacted] ម៉ាលីស និងខាងលិចទល់នឹងភ្លឺស្រែ ឱ្យទៅភាគីសហចុងចម្លើយគ្រប់គ្រងជាម្ចាស់កម្មសិទ្ធិ ។

២-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ភាគីសហចុងចម្លើយ ។

សាលក្រមនេះបានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់នៅថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០២០ និងប្រកាសជាសាធារណៈនៅថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០២០ ចំពោះមុខគូភាគី បើកផ្លូវប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

**ចៅក្រមជំនុំជម្រះ**

ហត្ថលេខា និងត្រា

[redacted]

.....................................................................................................

**ច្បាប់ចម្លងត្រឹមត្រូវតាមច្បាប់ដើម**

ថ្ងៃព្រហស្បតិ៍ ៣រោច ខែមិគសិរ ឆ្នាំជូត ទោស័ក ព.ស២៥៦៤

ធ្វើនៅស្វាយរៀង ថ្ងៃទី០៣ ខែធ្នូ ឆ្នាំ ២០២០

**ក្រឡាបញ្ជី**

[redacted]

**បានឃើញ**

**ចៅក្រមជំនុំជម្រះ**

[redacted]